R.U.L.E

ELBBL

English Language Based
Bachelor of Law Program

LAW CLINIC

RULE - English Language Based
Bachelor of Law (ELBBL) Program

# ការលែងលះ







# មាតិកា


I. សេចក្តីផ្តើម

II. ការលែងលះ

- ១. ប្រភេទនៃការលែងលះ
- ២. មូលហេតុនៃការលែងលះ

III. នីតិវិធីនៃការលែងលះ

IV. អាហារកាតព្វកិច្ច និងសាហ៊ុយចិញ្ចឹមបីបាច់កូន

V. ការបែងចែកទ្រព្យ និងការកំណត់អំណាចមេបា

- ១. ការបែងចែកទ្រព្យ
- ២. ការកំណត់អំណាចមេបា

VI. អានុភាពនៃការលែងលះ

VII. នីតិវិធីនៃការរំលាយអនីតិសង្វាស

VIII. សេចក្តីសន្និដ្ឋាន

# I. សេចក្តីផ្តើម

មនុស្សយើងកើតមកសុទ្ធតែមានអារម្មណ៍ស្រលាញ់ និងអារម្មណ៍ស្អប់អ្នកខ្លះស្រឡាញ់គ្នារហូតដល់រៀបការជាមួយគ្នា ចំណែកអ្នកខ្លះទៀតបានរៀបការជាមួយគ្នាហើយក៏បែកគ្នាវិញ។ នៅក្នុងប្រទេសកម្ពុជា ការរៀបអាពាហ៍ពិពាហ៍មួយត្រូវបានចាត់ទុកថាត្រឹមត្រូវ និងមានការទទួលស្គាល់ដោយច្បាប់បានលុះត្រាតែភាគីទាំងពីរបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍ក៏ប៉ុន្តែដោយហេតុថាប្រជាជនមួយចំនួននៅក្នុងប្រទេសកម្ពុជាពួកគេមិនបានយល់ដឹងពីច្បាប់ហើយដោយសារតែកង្វះខាតនូវការណែនាំផងនោះទើបនាំអោយគូស្នេហ៍មួយចំនួនពុំបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍ដោយពួកគេយល់ច្រឡំថាឱ្យតែរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីពួកគេអាចរស់នៅជាមួយគ្នាបានហើយ។

ការរស់នៅជាមួយគ្នាដោយគ្មានសំបុត្រអាពាហ៍ពិពាហ៍បែបនេះតាមផ្លូវច្បាប់គឺមិនបានចាត់ទុកថាគូភាគីមានចំណងអាពាហ៍ពិពាហ៍នោះទេ ករណីនេះនៅក្នុងច្បាប់ត្រូវបានចាត់ទុកថាជាចំណងអនីតិសង្វាស (ការរស់នៅលក្ខណៈជាសង្សារ)។ បញ្ហាដែលកើតមាននោះគឺនៅពេលដែលគូភាគីនៃចំណងអាពាហ៍ពិពាហ៍ ឬចំណងអនីតិសង្វាសមិនអាចរួមរស់ជាមួយគ្នាបានតទៅទៀត តើពួកគេត្រូវធ្វើការផ្តាច់ចំណងនីតិសង្វាស និងអនីតិសង្វាសនៅកន្លែងណា និង នីតិវិធិនៃការបែងចែកកូន និងទ្រព្យសម្បត្តិប្រព្រឹត្តិទៅយ៉ាងដូចម្តេច ?

ដើម្បីឱ្យមានការយល់ដឹងអំពីនីតិវីធីក្នុងការផ្តាច់ចំណងនេះឱ្យកាន់តែច្បាស់ទើបពួកយើងសម្រេចចិត្តបង្កើតឯកសារនេះឡើង ដើម្បីជាថ្នាលក្នុងការផ្តល់ជាចំណេះដឹងទូទៅពាក់ព័ន្ធទៅនឹងបញ្ហានេះ។

# II. ការលែងលះ

ការលែងលះ គឺជាការរំលាយចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ រវាងប្ដី និងប្រពន្ធ ដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។



## ១. ប្រភេទនៃការលែងលះ

ការលែងលះត្រូវបានបែងចែកជាពីរ គឺ

- ការលែងលះតាមការព្រមព្រៀង និង
- ការលែងលះដោយគ្មានការព្រមព្រៀង ឬប្ដឹងលែងលះ។





# ២. មូលហេតុនៃការលែងលះ

មាត្រា **៩៧៨** នៃក្រមរដ្ឋប្បវេណីបានចែងដូចខាងក្រោម៖

**ក. បើបានប្រព្រឹត្តអំពើផិត ទៅលើសហព័ទ្ធ**



ឧទាហរណ៍៖ ភាគីប្ដីបានលួចលាក់មានស្រីកំណាន់ ដោយក្បត់ទៅនឹងមនោសញ្ចេតនារបស់ប្រពន្ធរបស់ខ្លួន។

**ខ. បើបានបោះបង់សហព័ទ្ធចោល ដោយគ្មានមូលហេតុត្រឹមត្រូវ**



ឧទាហរណ៍៖ ភាគីប្ដី ឬប្រពន្ធបានបាត់វត្តមានពីលំនៅដ្ឋាន ឬបាត់ខ្លួនដោយគ្មានមូលហេតុ ដែលធ្វើអោយភាគីប្ដីឬប្រពន្ធម្ខាងទៀតនោះមិនអាចទំនាកទំនងឬដឹងពីសុខទុក្ខបាន

**គ. បើមិនដឹងច្បាស់ថាសហព័ន្ធស្លាប់ ឬ រស់ អស់រយៈពេលជាង ១ឆ្នាំ**

មូលហេតុនេះគឺស្រដៀងទៅនឹងចំណុច “ខ” ខាងលើនេះដែរ

**ឃ.បើសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ អស់រយៈពេលជាង ១ ឆ្នាំ ផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍**

ឧទាហរណ៍៖ ភាគីប្រពន្ធបានចាកចេញពីលំនៅដ្ឋានដោយមិនរស់នៅជាមួយភាគីប្ដីជាងមួយឆ្នាំ។ វាខុសពីគោលបំណងនៃអាពាហ៍ពិពាហ៍ ព្រោះគោលបំណងអាពាហ៍ពិពាហ៍គឺដើម្បីរកសុភមង្គលដែលចេញពីការ រួមរស់នៅជាមួយគ្នា



ង. ករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន។



ឧទាហរណ៍៖ ភាគីទាំងពីរ រស់នៅជាមួយគ្នាមានតែជម្លោះដែលធ្វើអោយអស់មនោសញ្ចេតនានឹងគ្នា ហើយជម្លោះចេះតែបន្ត ដោយគ្មានសង្ឃឹមថានឹងអាចត្រូវគ្នាវិញនោះទេ។

# III. នីតិវិធីនៃការលែងលះ

## ១. ការលែងលះដោយការព្រមព្រៀង

ការលែងលះដោយការព្រមព្រៀងសំដៅដល់ភាគីប្ដី និងប្រពន្ធព្រមព្រៀងគ្នា ក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍។ តុលាការអាចឱ្យភាគីទាំងសងខាងលែងលះគ្នាបាន នៅពេលដែលតុលាការយល់ឃើញថា ភាគីទាំងសងខាងពិតជាមានបំណងក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ពិតប្រាកដមែន។

គូភាគីត្រូវធ្វើកិច្ចព្រមព្រៀងលែងលះ ១ច្បាប់ដែលកំណត់ពីការលែងលះ ការបែងចែកកូន និងទ្រព្យសម្បត្តិ (ករណីដែលមានកូន និងទ្រព្យសម្បត្តិ) និងពាក្យស្នើសុំលែងលះ ដើម្បីស្នើសុំទៅតុលាការក្នុងការចេញដីកាសម្រេច រំលាយចំណងអាពាហ៍ពិពាហ៍។







ដែនសមត្ថកិច្ចរបស់តុលាការនៅក្នុងការលែងលះដោយការព្រមព្រៀងនេះគឺត្រូវកំណត់ទៅតាមទីកន្លែងដែលគូភាគីស្នាក់នៅ។ មុនពេលគូភាគីសម្រេចដាក់ពាក្យស្នើសុំលែងលះគូភាគីទាំងសងខាងត្រូវតែប្រាកដថាខ្លួនបានសម្រេចទៅលើអំណាចមេបារួចរាល់ហើយ ក៏ព្រោះថាប្រសិនបើគូភាគីទាំងសងខាងបានសម្រេចលើអំណាចមេបារួចរាល់ហើយតុលាការនឹងអាចចេញសាលដីកាសម្រេចដែលមានខ្លឹមសាររំលាយចំណងអាពាហ៍ពិពាហ៍។

យោងទៅតាមតារាងនៃនីតិវិធីលែងលះរបស់ JICA បានលើកការពន្យល់មកបន្ថែមថា គូភាគីគឺជម្រុញអោយសម្រេចលើអំណាចមេបារួចរាល់ព្រោះថា ប្រសិនបើគូភាគីពុំបានសម្រេចលើអំណាចមេបានោះទេ តុលាការមិនអាចចេញដីការសម្រេចទទួលពាក្យសុំលែងលះនោះបានទេ ហេតុដោយសារតែខ្លាច បាត់បង់ផលប្រយោជន៍របស់កូនដែលនាំអោយកូនពុំបានទទួលការផ្គត់ផ្គង់ពេញលេញពីឪពុកម្តាយ។



- **គំរូនៃពាក្យស្នើសុំលែងលះ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យស្នើសុំលែងលះតាមការព្រមព្រៀង**

**ដើមចោទ** ៖ ឈ្មោះ **ហេង នេច** ភេទស្រី អាយុ៤១ឆ្នាំ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ: 02389292208 មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ផ្លូវ ភូមិ សង្កាត់ ខណ្ឌ៧មករា ភ្នំពេញ។

**ចុងចម្លើយ** ៖ ឈ្មោះ**ឡុង លីរាជ** ភេទប្រុស អាយុ ៥០ ឆ្នាំ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ: 00453243243 មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ 18B ផ្លូវ ភូមិ សង្កាត់ ខណ្ឌ៧មករា ភ្នំពេញ។

**សូមគោរពចូលមក**

**ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ**៖ សុំឱ្យតុលាការចេញដីកាសម្រេចមានខ្លឹមសារដូចខាងក្រោម៖

ឱ្យដើមចោទ និងចុងចម្លើយ ផ្តាច់សមគ្គសង្វាស់តាមផ្លូវច្បាប់។

**យោង** ៖ -សំបុត្រអាពាហ៍ពិពាហ៍លេខ 168 ចុះថ្ងៃទី 15 របស់ តាង្វូន ។

តបតាមកម្មវត្ថុខាងលើ យើងខ្ញុំសូមជម្រាបជូន ឯកឧត្តមប្រធាន មេត្តាជ្រាបថា ៖ យើងខ្ញុំបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅសាលាសង្កាត់ កាកាប តាមលិខិតលេខ 168 ចុះថ្ងៃទី 19។ នៅពេលនេះ យើងខ្ញុំបានអស់មនោសញ្ចេតនាក្នុងការរស់នៅជាប្តីប្រពន្ធនឹងគ្នាទៀតហើយ។ យើងខ្ញុំបានព្រមព្រៀងលែងលះគ្នាដោយស្ម័គ្រចិត្ត។

អាស្រ័យហេតុនេះ សូមឯកឧត្តមប្រធាន មេត្តាទទួល និងសម្រេចតាមការស្នើសុំខាងលើដោយក្តីអនុគ្រោះ។

សូមឯកឧត្តមកប្រធាន ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ធ្វើនៅ........ថ្ងៃទី........ខែ........ឆ្នាំ...........

ស្នាមមេដៃស្តាំដើមចោទ                ស្នាមមេដៃស្តាំចុងចម្លើយ

- **<u>គំរូនៃកិច្ចព្រមព្រៀងលែងលះ</u>**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**<u>កិច្ចព្រមព្រៀងលែងលះ</u>**

កិច្ចព្រមព្រៀងនេះធ្វើឡើងនៅថ្ងៃទី......ខែ.......ឆ្នាំ២០២១

**រវាង**

ឈ្មោះ **ចាន ស្រីពិច** ភេទស្រី ថ្ងៃខែឆ្នាំកំណើត កាន់អត្តសញ្ញាណបណ្ណលេខ 090232303 មាន អាសយដ្ឋានស្ថិតនៅផ្ទះWF៨៤ Eo ផ្លូវទី០៥ ភូមិ កែង សង្កាត់ សង្កាត់បឹងកេងកងទី ១ ខណ្ឌ អូឡាំពិក រាជធានី-ភ្នំពេញ តទៅនេះហៅកាត់ថាភាគី (ក)។

**និង**

ឈ្មោះ **ឡុង ស៊ីមង** ភេទប្រុស ថ្ងៃខែឆ្នាំកំណើត ឆ្នាំកាន់អត្តសញ្ញាណបណ្ណលេខ 0234580292 មាន អាសយដ្ឋានស្ថិតនៅ ផ្ទះWF៨៤ Eo ផ្លូវទី..2004 ភូមិតាងួន១ សង្កាត់កាកាបទី១, ខណ្ឌពោធិ៍សែនជ័យ, រាជធានីភ្នំពេញ តទៅនេះហៅកាត់ថាភាគី (ខ)។

ដោយហេតុថាភាគី (ក) និងភាគី (ខ) បានរៀបការជាមួយគ្នា ហើយបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ នៅសាលាសង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ហើយបង្កើតបានកូនចំនួន០១ នាក់ ភេទប្រុស កើតនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៦។ ដោយការរួមរស់ជាមួយគ្នាជាប្ដីប្រពន្ធតែងតែមានភាពរកាំរកូស និងមិនចុះសម្រុងគ្នាដែលនាំឱ្យភាគីទាំងសងខាងមិនអាចបន្តរួមរស់ជាមួយគ្នាជាប្ដីប្រពន្ធទៀតបាន ភាគី (ក) និងភាគី (ខ) បានព្រមព្រៀងគ្នាលែងលះឈប់រស់នៅជាប្ដីប្រពន្ធចាប់ពីពេលនេះតទៅ។

**ក្រោយពីបានពិភាក្សាគ្នារួចមកភាគីទាំងពីរបានឯកភាពគ្នាដូចខាងក្រោម៖**

ប្រការ១ ៖ អំពីការលែងលះ

ភាគី (ក) និង (ខ) បានយល់ព្រមលែងលះគ្នា ចាប់ពីពេលនេះតទៅ ដោយផ្អែកលើកិច្ចព្រមព្រៀងនេះ ដោយគ្មានការបង្ខិតបង្ខំឡើយ ដោយមូលហេតុថាខ្លួនអស់មនោសញ្ចេតនាក្នុងការរួមរស់ជាមួយគ្នាក្នុងនាមជាប្ដីប្រពន្ធ។

ប្រការ២ ៖ អំពីកូនខ្ញុំ

២.១.　ផ្តល់សិទ្ធឱ្យភាគី (ក) ជាអ្នកមានសិទ្ធអំណាចមេបាលើកូន ឈ្មោះ **ឡុង លីគង** ភេទប្រុសកើតនៅថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ២០១៦។

២.២.　ភាគី (ខ) យល់ព្រមបង់អាហារកាតព្វកិច្ចចិញ្ចឹមកូនចំនួន ១៥០ ( មួយរយហាសិប) ដុល្លារអា-មេរិក ក្នុង០១ខែ និងបង់បន្ថែមតាមលទ្ធភាពដែលមានសម្រាប់តម្រូវការសិក្សាជាក់ស្តែង ឬក្នុងករណីមានជំងឺផ្សេងៗ រហូតដល់កូនមានវ័យនីតិភាព។

២.៣.　ភាគី (ខ) មានសិទ្ធចូលជួបកូន ឬអាចនាំកូនដើរលេងបាន តែចាំបាច់ត្រូវជូនដំណឹងដល់ភាគី (ក)ឱ្យបានដឹងជាមុន។

ប្រការ៣ ៖ អំពីទ្រព្យសម្បត្តិ

៣.១.　ភាគី (ក) ជាអ្នកទទួលបាន ផ្ទះ០១ (មួយ)ល្វែង ទំហំទទឹង ៤.១០ម៉ែត្រ និងបណ្តោយ១៥.៧០ម៉ែត្រ ដែលមានទីតាំងស្ថិតនៅ ផ្លូវ 2004 ភូមិតាងួន១ សង្កាត់កាកាបទី១, ខណ្ឌពោធិ៍សែនជ័យ, រាជធានីភ្នំពេញ

៣.២.　ភាគី(ក) ត្រូវប្រគល់ប្រាក់ចំនួន ១០០០ ( មួយពាន់) ដុល្លារអាមេរិក មកឱ្យភាគី (ខ) បន្ទាប់ពីពីចេញដីកាសម្រេចលើការលែងលះដោយព្រមព្រៀងនេះហើយ។

ប្រការ៤៖ អំពីបំណុល

ក្នុងករណីដែលភាគី(ក) ឬ(ខ) មានបំណុលរៀងៗខ្លួនដែលលាក់លៀមមិនឱ្យភាគីណាមួយបានដឹងក្នុងកំឡុងពេលអាពាហ៍ពិពាហ៍ នោះភាគីទាំងសងត្រូវទទួលខុសត្រូវរៀងៗខ្លួន។

ប្រការ៤៖ អន្តរបញ្ញត្តិ

គូភាគីបានអាន និងយល់នូវរាល់អត្ថន័យគ្រប់ចំណុចនៃកិច្ចសន្យានេះ ហើយសន្យាថានឹង អនុវត្តតាមប្រការនីមួយៗ នៃកិច្ចសន្យានេះដោយម៉ឺងម៉ាត់ មិនឱ្យខុសទៅនឹងប្រការណាមួយនៃកិច្ចសន្យានេះឡើយ ហើយយល់ព្រមផ្តិតស្នាមមេដៃស្តាំទុកជាភស្តុតាង។

កិច្ចសន្យានេះធ្វើឡើងជាភាសាខ្មែរ ចំនួន០៤ ច្បាប់ ដោយរក្សាទុកនៅភាគី(ក) ០១ ច្បាប់ ភាគី(ខ) ០១ច្បាប់ ការិយាល័យមេធាវី០១ ច្បាប់ និងដាក់ជូនតុលាការចំនួន០១ច្បាប់។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ២០២១

ស្នាមមេដៃស្តាំភាគី(ខ) ស្នាមមេដៃស្តាំភាគី(ក )

**បានឃើញ និងបញ្ជាក់ថាៈ**

គូភាគីបានផ្តិតមេដៃចំពោះមុខមេធាវីប្រាកដមែន។

ហត្ថលេខា និងត្រា

# ២. ការលែងលះដោយគ្មានការព្រមព្រៀង ឬប្ដឹងលែងលះ

ការលែងលះដោយគ្មានការព្រមព្រៀង ឬប្ដឹងលែងលះ សំដៅលើ ប្ដី ឬប្រពន្ធ ពុំមានឆន្ទៈក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍។





## តើការផ្ដាច់ចំណងអាពាហ៍ពិពាហ៍អាចធ្វើឡើងដោយក្រុមប្រឹក្សាឃុំសង្កាត់ដែរឬទេ ?

ក្រុមប្រឹក្សាឃុំសង្កាត់មិនអាចផ្ដាច់ចំណងអាពាហ៍ពិពាហ៍បានទេ មានតែតុលាការដែលអាចធ្វើការផ្ដាច់ចំណងអាពាហ៍ពិពាហ៍បាន។

ភាគីអាចដាក់ពាក្យបណ្ដឹងលែងលះនៅក្រុមប្រឹក្សាឃុំសង្កាត់បាន ហើយក្រុមប្រឹក្សាឃុំសង្កាត់នឹងធ្វើការបញ្ចុះបញ្ចូលឱ្យសះជាគ្នានៅក្នុងអំឡុងពេល ១៥ថ្ងៃ បន្ទាប់ពីទទួលបានពាក្យបណ្ដឹងនោះ។ ប្រសិនបើមិនអាចបញ្ចុះបញ្ចូលឱ្យសះជាបានទេពាក្យបណ្ដឹងលែងលះនឹងត្រូវបញ្ជូនទៅតុលាការជាបន្ទាន់។

## តើការដាក់ពាក្យបណ្ដឹងលែងលះត្រូវធ្វើឡើងយ៉ាងដូចម្ដេចខ្លះ ?

- បណ្ដឹងលែងលះត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរដោយមានបញ្ជាក់ពីមូលហេតុនៃការលែងលះ
- ពាក្យបណ្ដឹងនេះគឺត្រូវធ្វើឡើងស្របទៅតាមមាត្រា៧៥ នៃក្រមរដ្ឋប្បវេណីដូចការសរសេរបណ្ដឹងផ្សេងទៀតដែរ គឺតម្រូវឱ្យមាននូវឈ្មោះ អាសយដ្ឋានរបស់គូភាគី មូលហេតុនៃពាក្យបណ្ដឹង និងកម្មវត្ថុដែលភាគីទាមទារអោយតុលាការចេញ
- បន្ទាប់ពីសរសេរពាក្យបណ្ដឹងស្របតាមមាត្រា៧៥នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្តីឬប្រពន្ធ ត្រូវយកទៅដាក់នៅរដ្ឋបាលតុលាការ រាជធានី/ខេត្ត ឬក្រុង ដែលភាគីស្នាក់នៅ។ នៅពេលដាក់ពាក្យបណ្ដឹងរដ្ឋបាលសាលាដំបូង និងចេញក្រដាសដើម្បីឱ្យភាគីដើមចោទបង់ពន្ធលើពាក្យបណ្ដឹង។



- ក្រោយមក ក្នុងអំឡុងពេល១សប្តាហ៍ទៅ១៥ ថ្ងៃ តុលាការ និងទាក់ទងទៅភាគីខាងដើមចោទ ក្នុងការបង់ពន្ធ ប្រាក់ប្រដាក់ក្តីតុលាការក្រៅពីពន្ធ។ បន្ទាប់មក តុលាការ នឹងកោះហៅគូភាគីចូលរួមនីតិវិធីត្រៀមទាញហេតុផលដើម្បីកំណត់ចំណុចវិវាទ។
- នីតិវិធីចុងក្រោយគឺនីតិវិធីទាញហេតុផល។ តុលាការនឹងកំណត់កាលបរិច្ឆេទប្រកាសសាលក្រម ភាគីអាចប្តឹងឧទ្ធរណ៍បាន។

## ឯកសារចាំបាច់ដែលត្រូវភ្ជាប់ជាមួយនិងពាក្យបណ្តឹងទៅតុលាការ

ឯកសារចាំបាច់សម្រាប់ការដាក់ពាក្យបណ្តឹងលែងលះ  គឺមានលក្ខណៈខុសៗគ្នាទៅតាមរឿងក្តីនីមួយៗក៏ប៉ុន្តែខាងក្រោមនេះគឺជាឯកសារទូទៅដែលត្រូវមាននៅពេលដែលធ្វើការដាក់ពាក្យបណ្តឹង៖



- សំបុត្រអាពាហ៍ពិពាហ៍
- អត្តសញ្ញាណបណ្ណរបស់គូភាគី
- សំបុត្រកំណើតកូន(ប្រសិនបើមាន)
- សំបុត្របញ្ជាក់កម្មសិទ្ធអចលនវត្ថុនិងចលនវត្ថុ(ឯកសារភ្ជាប់ទុកជាភស្តុតាងដើម្បីឱ្យតុលាការសម្រេចលើការបែកចែកទ្រព្យសម្បត្តិ)
- ឯកសារបញ្ជាក់ពីបំណុលរួម (ប្រសិនបើមាន)



- # គំរូនៃពាក្យបណ្ដឹងលែងលះ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យបណ្ដឹង**

**ភាគីដើមចោទៈ** នាងខ្ញុំឈ្មោះ **យី ចិណា** អាយុ៤៦ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នៈមាន អាសយដ្ឋានស្ថិតនៅភូមិ តាងួន សង្កាត់ កាកាប ខេត្តពោធិ៍សាត់ ដែលមានមេធាវីតំណាងដោយ អាណត្តិ កញ្ញាមេធាវី **ម៉េង សាណា** លេខទូរស័ព្ទៈ ០១៧ ៦៩ ៤២ ៥៦/ ០៩៦ ៤០ ២៤ ៤២៣ ។

**ភាគីចុងចម្លើយៈ** ឈ្មោះ **ស៊ុំ វីរាក** ភេទប្រុស អាយុ ៥១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នៈ ភូមិ ចាសសង្កាត់ ថ្មីទី ខេត្តពោធិ៍សាត់។

**សូមគោរពចូលមក**

**ឯកឧត្តមប្រធានសាលាដំបូងខេត្តពោធិ៍សាត់**

**កម្មវត្ថុ:** ស្នើសុំតុលាការចេញសាលក្រមដែលមានខ្លឹមសារនៃការទាមទារដូចខាងក្រោមៈ

១. ឱ្យនាងខ្ញុំបានផ្ដាច់សមគ្គសង្វាសជាមួយប្ដីឈ្មោះ **ស៊ុំ វីរាក** តាមផ្លូវច្បាប់។

២. សុំសិទ្ធិគ្រប់គ្រងកូនចំនួន **០១**នាក់ ឈ្មោះ **ស៊ុំ និច** ភេទស្រី អាយុ ០៨ឆ្នាំ

៣. សុំឱ្យធ្វើការបែងចែកទ្រព្យសម្បត្តិរួម និងបំណុលជាពីរស្មើៗគ្នា

-ផ្ទះទំហំ ១៨ ម៉ែត្រការ៉េ ទទឹង១០ ម៉ែត្រការ៉េ និងបណ្ដោយ ៨ ម៉ែត្រការ៉េ ស្ថិតនៅភូមិ ដីថ្មី សង្កាត់ ភ្នំពេញចាស់ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។

-ដីលំនៅដ្ឋាន ទំហំ ២០ម៉ែត្រការ៉េ ស្ថិតនៅភូមិ តាងួន សង្កាត់ កាកាប ខេត្តពោធិ៍សាត់។

-ដីលំនៅដ្ឋានទំហំ ២០ ម៉ែត្រការ៉េ។

៤. បំណុលនៅជាប់ពាក់ប្អូនបង្កើតខាងប្រពន្ធនាពេលបច្ចុប្បន្ន មានចំនួនសរុប **៥០០០០(ប្រាំម៉ឺនដុល្លាអាមេរិក)** ខ្ចីដើម្បីទិញដី ទាំងពីរនាក់ប្ដីប្រពន្ធ។

៥. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ ។

តបតាមកម្មវត្ថុខាងលើ នាងខ្ញុំជាភាគីដើមចោទ សូមធ្វើពាក្យបណ្ដឹងមួយច្បាប់គោរពចូល **ឯកឧត្តម** ដោយស្នើសុំចេញសាលក្រមដូចដែលមានក្នុងកម្មវត្ថុខាងលើនេះ។ មូលហេតុនៃការស្នើសុំ ដោយយើងខ្ញុំមិនអាចរួមរស់ជាមួយគ្នាជាលក្ខណៈប្ដីប្រពន្ធបន្តទៀតបានទេ ដោយអស់មនោសញ្ចេតនា សេចក្ដីទុក្ខចិត្តគ្នា និងមានទំនាស់កើតឡើងក្នុងគ្រួសារ មានអំពើហិង្សាកើតឡើងទាំងផ្លូវកាយ និងផ្លូវចិត្តជាប្រចាំ ។លើសពីនេះទៀត នាងខ្ញុំមិនចង់ឱ្យប៉ះពាល់ដល់បញ្ហាសតិអារម្មណ៍ និងផ្លូវចិត្តរបស់កូន។ ហើយក្នុងអំឡុងពេល

នៃការរស់នៅជាមួយគ្នាកន្លងមក យើងខ្ញុំមានកូនស្រីមួយ(០១)នាក់ ដែលមានអាយុទើបតែ០៨ឆ្នាំ កំពុងរស់នៅក្នុងបន្ទុកជាមួយគ្នា ថែមទាំងរកបាននូវទ្រព្យសម្បត្តិមួយចំនួនដូចដែលមានស្នើសុំបែងចែកក្នុងកម្មវត្ថុខាងលើ ដើម្បីបញ្ចប់ក្នុងការរស់នៅជាមួយគ្នា និងបែងចែកទ្រព្យសម្បត្តិឱ្យមានភាពច្បាស់លាស់។

អង្គហេតុចាំបាច់ដែលនាងខ្ញុំត្រូវប្ដឹងចូលមកតុលាការ ដោយយើងខ្ញុំរស់នៅមិនចុះសម្រុងគ្នា មានអំពើហិង្សាក្នុងគ្រួសារមិនអាចបន្តរួមរស់ជាលក្ខណៈប្ដីប្រពន្ធ និងមិនអាចបែងចែកទ្រព្យសម្បត្តិឱ្យបានច្បាស់លាស់។ ដោយជួបហេតុផលលំបាកដូច្នេះ និងដើម្បីឱ្យតុលាការចេញសាលក្រមដូចដែលបានទាមទារខាងលើ ទើបនាងខ្ញុំសម្រេចចិត្តប្ដឹងមក **ឯកឧត្តម** មេត្តាជួយចំណាត់ការតាមនីតិវិធីផ្លូវច្បាប់ផង។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើសូម **ឯកឧត្តម** មេត្តាជួយចំណាត់ការចំពោះអំពីការលែងលះរបស់នាងខ្ញុំ និងការទាមទារដោយក្ដីអនុគ្រោះផង។

សូម **ឯកឧត្តម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ ។

ថ្ងៃពុធ ២កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

ធ្វើនៅខេត្តពោធិ៍សាត់,ថ្ងៃទី២៦ ខែតុលា ២០២២

**ស្នាមមេដៃស្ដាំ**

**សូមភ្ជាប់ឯកសារថតចម្លង៖**

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ

-សេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ (០១) ច្បាប់

-

# IV. អាហារកាតព្វកិច្ច និងសាហ៊ុយចិញ្ចឹមបីបាច់កូន

## ១. អាហារកាតព្វកិច្ច

អាហារកាតព្វកិច្ច សំដៅលើកិច្ចដែលត្រូវបំពេញតាមច្បាប់ ឬតាមសេចក្ដីសម្រេចរបស់តុលាការដែលតម្រូវអោយបុគ្គលម្នាក់ ឬច្រើននាក់ផ្ដល់ប្រាក់ ឬទ្រព្យដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅរបស់បុគ្គលផ្សេងទៀត ដែលមានទំនាក់ទំនងញាតិនឹងគ្នា។ ចំណងញាតិក៏កើតចេញពីការរៀបអាពាហ៍ពិពាហ៍ដែរ( មាត្រា ១១៤០ ដល់១១៤៨)។



## ២. អាហារកាតព្វកិច្ចសម្រាប់សហព័ន្ធ

ការផ្គត់ផ្គង់អាហារកាតព្វកិច្ចសម្រាប់សហព័ន្ធ គឺជាអានុភាពនៃអាពាហ៍ពិពាហ៍ស្របច្បាប់ដែលតម្រូវអោយជួយសង្គ្រោះគ្នាទៅវិញទៅមក(មាត្រា៩៦៦ ដល់៩៧១)។

នៅក្នុងករណីលែងលះ យោងតាមមាត្រា៧៦ និងមាត្រា ៧៧នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍និងគ្រួសារ បានកំណត់ថា៖

ភាគីដែលគ្មានកំហុសអាចស្នើសុំអាហារកិច្ចពីភាគីម្ខាងទៀតបាន ទៅតាមលទ្ធភាពរបស់ភាគីនោះ ឬតាមការព្រមព្រៀងរបស់ភាគីប្រសិនបើគ្មានការឯកភាពគ្នាទេ តុលាការនឹងសម្រេចផ្អែកលទ្ធភាពរបស់ភាគី។ ប៉ុន្តែប្រសិនបុគ្គលដែលទទួលអារហារកិច្ចនោះបានរៀបអាពាហ៍ពិពាហ៍ថ្មីហើយ បុគ្គលនោះនឹងលែងទទួលបានអាហារកិច្ចបន្តទៀតហើយ។

## ៣. សាហ៊ុយចិញ្ចឹមបីបាច់កូន

ឳពុក ឬម្តាយដែលមិនមានអំណាចមេបា ឬមិនរស់នៅជាមួយកូនក្រោយពេលលែងលះត្រូវមានករណីកិច្ចទទួលបន្ទុកសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន។ ក្រោយលែងលះឳពុក ឬម្តាយដែលមានកាតព្វកិច្ចផ្តល់សាហ៊ុយចិញ្ចឹមបីបាច់កូនដែលជាអនីតិជននោះត្រូវជាប់អាហារកិច្ចរហូតដល់កូននោះដល់អាយុក្លាយជានីតិជន ។ មានន័យថាករណីកិច្ចផ្តល់សាហ៊ុយចិញ្ចឹមបីបាច់កូនត្រូវមាន រហូតដល់កូននោះ មានអាយុ១៨ឆ្នាំ។



# V. ការបែងចែកទ្រព្យ និង ការកំណត់អំណាចមេបា

## ១. ការបែងចែកទ្រព្យ

ទ្រព្យសម្បត្តិត្រូវបានបែងចែកជាពីរ ទ្រព្យសម្បត្តិដោយឡែក ឬទ្រព្យសម្បត្តិបុគ្គល និងទ្រព្យសម្បត្តិរួម។



## ក. ទ្រព្យសម្បត្តិដោយឡែក ឬទ្រព្យសម្បត្តិបុគ្គល

យោងតាមមាត្រា ៩៧២ ទ្រព្យសម្បត្តិដោយឡែក ឬទ្រព្យសម្បត្តិបុគ្គល សំដៅទៅលើទ្រព្យសម្បត្តិដោយឡែក ដែលស្ថិតនៅក្រោមកម្មសិទ្ធរបស់សហព័ន្ធណាម្នាក់៖

- ទ្រព្យសម្បត្តិ ដែលសហព័ន្ធមាន នៅមុនពេលរៀបអាពាហ៍ពិពាហ៍

**ឧទាហរណ៍៖** ភាគីប្តីមានផ្ទះ និងឡានដែលខ្លួនបានទិញមុនពេលគាត់រៀបការ។

- ទ្រព្យសម្បត្តិ ដែលសហព័ន្ធទទួលបាន ដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍

**ឧទាហរណ៍៖** ឪពុកម្តាយរបស់ភាគីប្តីបានប្រគល់ដីមួយកន្លែងអោយទៅគាត់។

- ទ្រព្យសម្បត្តិដែលជាតម្លៃតបពីការចាត់ចែងទ្រព្យសម្បត្តិដែលបានចែងក្នុងពីរចំណុចខាងលើ។

**ឧទាហរណ៍៖** ក្នុងអំឡុងពេលដែលភាគីនៅជាប្តីប្រពន្ធស្របច្បាប់ ភាគីប្រពន្ធបានយកផ្ទះដែលខ្លួនបានទិញនៅពេលខ្លួលមិនទាន់រៀបការនោះទៅលក់។ ក្នុងករណីនេះ លុយដែលទទួលបានពីការលក់ផ្ទះនោះចាត់ទុកជាទ្រព្យសម្បត្តិដោយឡែក ពោលគឺ ជាកម្មសិទ្ធរបស់ភាគីប្រពន្ធ។





## ខ. ទ្រព្យសម្បត្តិរួម

យោងតាមមាត្រា ៩៧៣ ទ្រព្យសម្បត្តិរួម សំដៅលើទ្រព្យសម្បត្តិរួម សំដៅលើទ្រព្យសម្បត្តិណាមួយដែលភាគីទទួលបានក្នុងអំឡុងពេល ឬក្រោយពេលរៀបការ។ ភាគីទាំងពីរមានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ និងទទួលបានអត្ថប្រយោជន៍ពីទ្រព្យសម្បត្តិរួម។





**ឧទាហរណ៍៖** ពេលរៀបការ ប្តីទិញដីមួយកន្លែងហើយចុះបញ្ជីតែឈ្មោះរបស់គាត់ក្នុងលិខិតបញ្ជាក់កម្មសិទ្ធិដី។ ភាគីទីបីចង់ទិញដីពីប្តី។ ក្នុងករណីនេះ ប្តីក៏ត្រូវការការយល់ព្រមពីប្រពន្ធដែរ ដើម្បីលក់ដី។ ហេតុផលគឺផ្អែកលើមាត្រា៩៧៦(១)នៃក្រមរដ្ឋប្បវេណីកម្ពុជាទ្រព្យសម្បត្តិមិនអាចលក់បានដោយគ្មានការយល់ព្រមពីប្តីប្រពន្ធទាំងពីរនោះទេ។បើទោះជាដីត្រូវបានចុះបញ្ជីតែក្នុងនាមប្តីក៏ដោយក៏ប្រពន្ធមានកម្មសិទ្ធិរួមគ្នានៃដីតាមរយៈប្រព័ន្ធអាពាហ៍ពិពាហ៍ស្របច្បាប់។

ភាគច្រើនតុលាការនឹងបែងចែកទ្រព្យសម្បត្តិជាពាក់កណ្តាលសម្រាប់ភាគីទាំងពីរ។ ប៉ុន្តែប្រសិនបើភាគីណាមួយមិនយល់ព្រមតុលាការនឹងពិចារណាលើកាលៈទេសៈដូចជា៖

- ការរួមចំណែករបស់សហព័ទ្ធនីមួយៗ
- ការថែទាំ និងបង្កើនទ្រព្យសម្បត្តិរយៈពេលនៃអាពាហ៍ពិពាហ៍
- កម្រិតជីវភាពក្នុងអាពាហ៍ពិពាហ៍
- អាយុរបស់ភាគីនីមួយៗ
- ផ្លូវចិត្ត ស្ថានភាពរាងកាយរបស់ប្តីប្រពន្ធ
- មុខរបរ ប្រាក់ចំណូល និងសមត្ថភាពរកប្រាក់ចំណូល
- សុខុមាលភាពរបស់កុមារ និងកត្តាស្រដៀងគ្នាផ្សេងៗទៀត។





## ២. ការកំណត់អំណាចមេបា

ទាក់ទងនឹងអំណាចរបស់មាតាបិតាមុនពេលតុលាការចេញសាលក្រមទាក់ទងនឹងការលែងលះអំណាចមាតាបិតាគឺជារឿងសំខាន់មួយពីព្រោះច្បាប់មិនអនុញ្ញាតឱ្យចេញសាលក្រមដោយមិនកំណត់អំណាចមាតាបិតាដែលតុលាការមានកំណត់អ្នកកាន់អំណាចមាតាបិតានៅក្នុងករណីដូចតទៅ៖

(១)ក្នុងករណីមានការលែងលះគ្នារវាងឪពុកម្តាយទាំងពីរឪពុក និងម្តាយត្រូវចរចាថាតើអ្នកណានឹងក្លាយជាអ្នកកាន់អំណាចមាតាបិតារបស់កុមារ។
(២)ប្រសិនបើឪពុក និងម្តាយលែងលះគ្នាមុនពេលដែលកូនកើតមកម្តាយត្រូវមានអាណាព្យាបាលនៅពេលកូនកើតមក។ ទោះយ៉ាងណាក៏ដោយឪពុក និងម្តាយអាចសម្រេចចិត្តបន្ទាប់ពីកូនកើតមកតាមរយៈការចរចាថាតើឪពុកអាចគ្រប់គ្រងកូនបានឬអត់។

(៣)តុលាការនឹងសម្រេចថាតើអ្នកណានឹងកាន់អំណាចបន្ទាប់ពីបាន
ពិចារណាលើផលប្រយោជន៍ល្អបំផុតរបស់កុមារប្រសិនបើភាគីមិនអាចចរចាជាមួយ
គ្នាបាន ឬប្រសិនបើការសម្រេចចិត្តក្នុងកថាខណ្ឌ(១)ឬ(២)មិនអាចសម្រេចបាន
បន្ទាប់ពីនីតិវិធីនៃការផ្សះផ្សារវាងភាគីទាំងពីរ។





# ក. ការកំណត់អំណាចមេបាក្នុងអំឡុងពេលនៃការលែងលះ

## ក. បើការចរចាមិនមានការផ្សះផ្សាតើអ្នកណានឹងទទួលបន្ទុកលើការចិញ្ចឹមកូន?

ក្នុងករណីដែលការចរចារវាងភាគីទាំងសងខាងមិនដំណើរការនោះសំណុំរឿងនឹងបញ្ជូនទៅតុលាការដើម្បីទាមទារសិទ្ធិក្នុងការចិញ្ចឹមបីបាច់កូនដូចមានចែងក្នុងមាត្រា១០៣៧(៣):

- កំណត់ថាតុលាការនឹងសម្រេចថាអ្នកណានឹងកាន់អំណាចមេបាបន្ទាប់ពីពិចារណារួច។ផលប្រយោជន៍ល្អបំផុតរបស់កូនដែលជាអនីតិជន(ពោលគឺកូនដែលមានអាយុក្រោមអាយុ18ឆ្នាំប្រសិនបើឪពុកម្តាយ/មាតាបិតាមិនអាចផ្សះផ្សាគ្នាបាន ឬប្រសិនបើការសម្រេចចិត្ត ក្នុងកថាខណ្ឌទី(1)ឬ(2)នៃច្បាប់ដូចគ្នាមិនអាចសម្រេចបានបន្ទាប់ពីការផ្សះផ្សារវាងភាគីទាំងពីរ។
- តុលាការនឹងកំណត់អំណាចមេបាដោយផ្អែកទៅលើផលប្រយោជន៍របស់កូនដែលជាអនីតិជននឹងអាចត្រូវបានពិចារណាដោយការកំណត់ទៅលើ(1)លក្ខខណ្ឌនៃឪពុក ឬម្តាយ;(2)ស្ថានភាពរបស់កូន,(3)លក្ខខណ្ឌរបស់ឪពុក ឬម្តាយ ថាតើពួកគាត់មានលទ្ធភាពទទួលខុសត្រូវទាំងស្រុងចំពោះកូន(ដែលពិចារណាយោងទៅលើស្ថានភាពសុខភាព ស្ថានភាពសេដ្ឋកិច្ចទ្រព្យសម្បត្តិនិងតម្រូវការដើម្បីទទួលខុសត្រូវលើកូន)។

ជាទូទៅការផ្សះផ្សារវាងមាតាបីតាទៅលើការទាមទារ ឬកំណត់អំណាចមេបាគឺអាស្រ័យទៅតាមករណីមួយទៅករណីមួយ ដូចដែលបានលើកឡើងនៅក្នុងការបកស្រាយខាងលើនេះ ឧទាហរណ៍: ក្នុងករណីដែលវិធានការចរចារវាងគូរភាគីទាំងពីរមិនដំណើរការទៅតាម នីតិវិធីរបស់តុលាការនោះ តុលាការនិងសម្រេចអំណាចមេបា អ្នកណាជាអ្នកទទួលសិទ្ធិក្នុងការមើលថែកូន ដោយមើលទៅលើកម្មវត្ថុនៅក្នុងសំណុំរឿង ដែលភាគីទាំងសងខាងបានដាក់មកតុលាការ មើលទៅលើស្ថានភាពសេដ្ឋកិច្ចរបស់ភាគីទាំងសងខាង និងពិចារណាដោយផ្អែកទៅលើផលប្រយោជន៍របស់កូនដែលជាកុមារ។





# VI. អានុភាពនៃការផ្តាច់ចំណងអាពាហ៍ពិពាហ៍

## ១. អានុភាពផ្តាច់ចំណងញាតិពន្ធ

យោងតាមមាត្រា ៩៤១ ការលែងលះមានអានុភាពធ្វើអោយរំលត់ចំណងញាតិពន្ធ។ ប៉ុន្តែគួរបញ្ជាក់ថាវាមិនមានអានុភាពធ្វើអោយរំលត់ចំណងជាមួយកូននោះទេ។





ឧទាហរណ៍៖ ភាគី ក និងភាគី ខ បានលែងលះគ្នាជាស្ថាពរ។ ទំនាក់ទំនងបងប្អូន ឬសាច់ញាតិរបស់ភាគី ក លែងជាញាតិរបស់ភាគី ខ ទៀតហើយ។ ប៉ុន្តែកូនៗនៅតែជាកូនរបស់ភាគីទាំងពីរដដែលគ្មានការប្រែប្រួលនោះទេ។ទោះបីជាកូន ត្រូវបានតុលាការសម្រេចឱ្យទៅខាងម្តាយ ឬខាងឪពុកក៏ដោយ។



# ២. ការកំណត់អំណាចមេបាបន្ទាប់ពីការលែងលះ

## តើក្រោយពេលលែងលះអ្វីខ្លះដែលត្រូវផ្តល់ឱ្យកូន?

- បន្ទាប់ពីការលែងលះឪពុកឬម្តាយដែលទទួលបានអំណាចមេបាមានសិទ្ធិ និងកាតព្វកិច្ចអប់រំកូនដែលជាអនីតិជន នឹងត្រូវរស់នៅកន្លែងដែលជ្រើសរើសដោយអ្នកកាន់អំណាចមេបាហើយគាត់អាចអប់រំកូនដោយផ្ទាល់ទៅតាមកម្រិតដែលតម្រូវទៅតាមច្បាប់។
- កូនដែលជាអនីតិជនមិនអាចចូលរួមក្នុងការងារណាមួយដោយគ្មានការអនុញ្ញាតពីអ្នកកាន់អំណាចមេបា ឬក្នុងលក្ខខណ្ឌដែលអនីតិជនត្រូវបានអនុញ្ញាតឱ្យធ្វើអាជីវកម្មអ្នកកាន់អំណាចមេបាអាចបញ្ចប់ ឬកំណត់ការអនុញ្ញាតដែលផ្តល់បាន។
- អ្នកដែលទទួលបានអំណាចមេបាអាចទាមទារឱ្យឪពុក ឬម្តាយដែលមិនមានអំណាចមេបាប្រគល់កូនមកវិញ ក្នុងករណីដែលភាគីដែលមិនមានអំណាចមេបាយកកូនទៅដោយមិនមានការទទួលដឹងលឺពីអ្នកកាន់អំណាចមេបា ឬក្នុងករណីដែលភាគីដែលមិនមានអំណាចមេបាយកកូនទៅលើសពីការកំណត់របស់តុលាការ។ លើសពីនេះ ភាគីដែលមិនបានទទួលអំណាចមេបាមានសិទ្ធិទៅសួរសុខទុក្ខកូនៗរបស់គាត់។
- ភាគីដែលអ្នកកាន់អំណាចមេបា ត្រូវបង្កឱ្យមានលក្ខណៈងាយស្រួលដល់ភាគីម្ខាងទៀតក្នុងការមកសួរសុខទុក្ខកូន។
- ភាគីដែលមិនទទួលអំណាចមេបាមានសិទ្ធិ ដាក់ពាក្យបណ្តឹង នៅពេលណាមួយ ទៅកាន់តុលាការដើម្បីដកហូតសិទ្ធិរបស់ភាគីម្ខាងទៀតក្នុងការថែរក្សាកូន ប្រសិនបើក្នុងករណីផលប្រយោជន៍របស់កូនត្រូវបានរំលោភបំពាន។



# VII. នីតិវិធីនៃការរំលាយចំណងអនីតិសង្វាស

### ក. ការរំលាយចំណងអនីតិសង្វាស

ជាទូទៅការរំលាយអនីតិសង្វាស គឺជាដំណើរការនៃការបំពេញការលែងលះសម្រាប់គូស្វាមីភរិយាដែលរៀបការតាមប្រពៃណី ឬរស់នៅជាមួយគ្នាជាធម្មតាដោយមិនបានចុះសំបុត្រអពាហ៍ពិពាហ៍។ គូស្វាមីភរិយាដែលមិនមិនមានសំបុត្រអាពាហ៍ពិពាហ៍ មិនត្រូវបានចាត់ទុកថាបានរៀបការត្រឹមត្រូវតាមអត្ថន័យរបស់ផ្លូវច្បាប់នោះទេ។ ហេតុនេះ នៅពេលដែលភាគី ចង់លែងលះគ្នា ទៅតុលការ នោះតុលាការ នឹងលើកពេលបណ្ដឹងចោល ដោយសារភាគីមិនមានចំណងអាពាហ៍ពិពាហ៍ទេ ហេតុនេះមិនអាចស្នើសុំ ឬប្ដឹងសុំឱ្យតុលាការរំលាយចំណងអាពាហ៍ពិពាហ៍ឱ្យបានទេ។ ដូច្នេះ ភាគី អាចដាក់ពាក្យសុំលែងលះនៅតាមសាលាសង្កាត់បាន ឬ អាចរស់នៅបែកគ្នាតែម្ដងក៏បានដែរ ព្រោះការរស់នៅលក្ខណៈប្ដីប្រពន្ធដែលមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ប្រៀបដូចការរស់នៅជាមួយគ្នាលក្ខណៈគូសង្សារ។

### ខ. ការបែងចែកទ្រព្យសម្បត្តិ

ក្នុងករណីដែលភាគី មិនព្រមព្រៀងគ្នា ក្នុងការបែងចែកទ្រព្យ នោះភាគីអាចដាក់ពាក្យប្ដឹងទៅតុលាការក្នុងការបែងចែកទ្រព្យសម្បត្តិដូចខាងក្រោម៖

=> ទ្រព្យសម្បត្តិដែលបានទិញហើយដាក់ឈ្មោះ ២នាក់ ហៅថា សហកម្មសិទ្ធិ ភាគីត្រូវបែកចែកគ្នាតាម ការចូលចំណែកបរិច្ចាករបស់ភាគីនីមួយៗ។

=> ទ្រព្យសម្បត្តិដែលបានដាក់ឈ្មោះតែម្នាក់ ត្រូវចាត់ជាទ្រព្យបុគ្គល។ ប៉ុន្តែភាគីណាម្ខាង អាចធ្វើការទាមទារចំណែករបស់ខ្លួនបាន ករណីដែលខ្លួនបានចូលលុយក្នុងការទិញវត្ថុនោះ **តាមសេចក្ដីចម្រើនឥតហេតុ**។ ប៉ុន្តែត្រូវតែមានភស្តុតាង បញ្ជាក់ពីការចូលចំណែក។

### គ. ការបែងចែកកូន

ទាក់ទងនឹងការបែកចែកកូន ភាគីក៏អាចដាក់ពាក្យបណ្ដឹងមកតុលាការដូចគ្នា ករណីដែល មិនមានការព្រមព្រៀងគ្នា។

=> ជាគោលការណ៍ កូនដែលកើតចេញពីផ្ទៃម្ដាយ ជាកូនរបស់ម្ដាយ

=> ករណីដែលនៅក្នុងសំបុត្រកំណើត មានឈ្មោះឪពុក មានន័យថា ឪពុកទទួលកូនតាមសំបុត្រកំណើត

=> ភាគីអាចធ្វើការបញ្ជាក់ភស្តុតាងមកតុលាការ អំពីភាពជាម្ដាយ ឬឪពុក

តុលាការសម្រេចសេចក្ដី យោងតាមភស្តុតាង និងផលប្រយោជន៍កូន បទបញ្ញត្តិ ការបែងចែកកូន ចំពោះចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ត្រូវយកមកប្រើ។

# VIII. សេចក្តីសន្និដ្ឋាន

យោងតាមការបកស្រាយខាងលើយើងខ្ញុំយល់ឃើញថាការយល់ការបញ្ចប់ទំនាក់ទំនងណាមួយគឺវាគ្មានភាពងាយស្រួលនោះទេ ហើយក៏គ្មានអ្នកណាម្នាក់ចង់បញ្ចប់ទំនាក់ទំនងដែលខ្លួនមានជាមួយគ្នាអស់ពេលជាយូរមកហើយដែរ។ ប៉ុន្តែមិនមែនឱ្យតែមានទំនាក់ទំនងហើយធ្លាប់បានរួមរស់ជាមួយគ្នាសុទ្ធតែបន្តនៅជាមួយគ្នាបានជារៀងរហូតនោះទេ។ ហេតុនេះហើយទើបវាបង្កឱ្យមាននូវការលែងលះកើតឡើង។ ដោយហេតុថាពួកយើងបានមើលឃើញនូវកំណើននៃការលែងលះនាពេលបច្ចុប្បន្នទើបពួកយើងសម្រេចចិត្តបង្កើតឯកសារនេះឡើង។



ឯកសារនេះមិនមែនបង្កើតឡើងដើម្បីជំរុញឱ្យមានការលែងលះនោះទេ ក៏ប៉ុន្តែដោយមើលឃើញនូវកង្វះខាតនៃការយល់ដឹងផ្នែកនេះ និងកំណើននូវបញ្ហាដែលកើតមានក្នុងដំណើរនៃការលែងលះទើបយើងខិតខំព្យាយាមសិក្សាស្រាវជ្រាវ និងបង្កើតនូវឯកសារនេះឡើងដើម្បីកុំឱ្យមានការភ័ន្តច្រឡំអំពីនីតិវិធីនៃការលែងលះតទៅទៀត។

ការលែងលះត្រូវឆ្លងកាត់ច្រើនដំណាក់កាល ចំណាយទាំងពេលវេលាទាំងថវិកាហើយព្រមទាំងជះនូវផលវិបាកជាច្រើនដល់ទំនាក់ទំនងសង្គម ក៏ព្រោះថាប្រសិនបើសង្គមមួយសម្បូរនោះ បញ្ហាជាច្រើននឹងកើតមានមកលើសង្គមរស់នៅលើសពីនេះវាថែមទាំងធ្វើអោយប៉ះពាល់ដល់ស្មារតីក្មេងដែលជាទំពាំងស្នងឫស្សីទៀតផង។ ដូច្នេះយើងសូមធ្វើការសំណូមពរដល់គូនៃអាពាហ៍ពិពាហ៍រាល់ពេលមានជម្លោះឱ្យធ្វើការព្យាយាមសម្របសម្រួលគ្នាឱ្យអស់ពីសម្តភាពសិន និងធ្វើការគិតឱ្យបានម៉ត់ចត់មុននឹងសម្រេចចិត្តឈានទៅដល់ការលែងលះគ្នា។





# ឯកសារយោង


១. ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧
២. នីតិវិធិរដ្ឋប្បវេណី ឆ្នាំ ២០០៦
៣. ច្បាប់ស្តីពី នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ ២០១០
៤. ច្បាប់ស្តីពី នីតិវិធីបណ្តឹងទាក់ទង និងឋានៈបុគ្គល ឆ្នាំ ២០១០



ដឹកនាំដោយៈ

កញ្ញា ហ៊ីង វ៉ាន់ដាណែត

កញ្ញា ណៃ សុខម៉េង

រៀបរៀងដោយនិស្សិតៈ

កញ្ញា វង្ស ច័ន្ទរតនា

កញ្ញា នីន សុធារី

កញ្ញា សន សារ៉ាវីន

លោក ឡុង កង

# គាំទ្រដោយ៖

R.U.L.E

ELBBL
English Language Based Bachelor of Law Program

RAOUL WALLENBERG INSTITUTE
OF HUMAN RIGHTS AND HUMANITARIAN LAW

ស៊ុយអែត
Sverige

LAW CLINIC
RULE - English Language Based Bachelor of Law (ELBBL) Program

ឯកសារខាងលើនេះ គឺជាតម្រូវការមួយសម្រាប់ការបញ្ចប់វគ្គសិក្សាជំនាញវិជ្ជាជីវៈច្បាប់ (Professional Legal Skills) នៃកម្មវិធីសិក្សានីតិសាស្ត្រជាភាសាអង់គ្លេស (ELBBL) របស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាល័យសេដ្ឋកិច្ច (RULE) ដែលបានបង្កើតឡើងក្នុងគោលបំណងអប់រំ និងចែករំលែកចំណេះដឹងដល់បុគ្គលមួយចំនួននិងយុវជនដែលមិនទាន់យល់យ៉ាងស៊ីជម្រៅទៅលើនីតិវិធីនៃការលែងលះ។ យើងខ្ញុំរីករាយទទួលស្វាគមន៍ចំពោះសំណួរ និងមតិសម្រាប់ធ្វើការកែសម្រួលឲ្យបានកាន់តែល្អប្រសើរដើម្បីធ្វើកិច្ចការស្រាវជ្រាវមួយនេះការមានភាពងាយស្រួលក្នុងការសិក្សាយល់ដល់អ្នកដែលនិងត្រូវការយកកិច្ចការស្រាវជ្រាវមួយនេះទៅសិក្សា និងចែករំលែកបន្ថែម។